00357074

D130/9/1

**Declassified to Public**
**12 April 2013**

នៅចំពោះមុខអង្គបុរេជំនុំជម្រះ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ)
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង ធីរិទ្ធ
ដាក់ជូន: អង្គបុរេជំនុំជម្រះ
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 31 / 07 / 2009
ម៉ោង (Time/Heure) : 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Tuy

<u>ចំណាត់ថ្នាក់ឯកសារ</u>
ចំណាត់ថ្នាក់ឯកសារ សាធារណៈ
ស្នើឡើងដោយភាគីដាក់ឯកសារ:
ចំណាត់ថ្នាក់ឯកសារដោយ កសចស
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់
ណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 03 / AUG / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Tuy

---

សំណើជាបន្ទាន់របស់មេធាវីការពារស្នើសុំពន្យាពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើចកស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម"

---

<u>ដាក់ដោយ៖</u>
**សហមេធាវីរបស់លោក អៀង ធីរិទ្ធ**
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC

**មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង ដើមបណ្តឹងរដ្ឋប្បវេណីគ្មានតំណាងទាំងអស់**

<u>ផ្ញើជូន៖</u>
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម ន័យ ផុល
ចៅក្រម ហួត វុទ្ធី
ចៅក្រម Katinka LAHUIS
ចៅក្រម Rowan DOWNING
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Robert PETIT

1. នៅពីថ្ងៃទី ២៨ ខែ កក្កដា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬ ដែលអាចបានមកពីការធ្វើទារុណកម្ម" ដែលត្រូវបានជូនដំណឹងមកមេធាវីការពារក្តីនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៩។ មេធាវីការពារក្តីបានដាក់សេចក្តី ជូនដំណឹងពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩[1]។

2. វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុងចែងថា:

   តាមរយៈពាក្យបណ្តឹងរបស់ភាគីពាក់ព័ន្ធ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចៈ

   ក) ពន្យាពេលវេលាកំណត់ ដែលខ្លួនបានសម្រេច [...]

3. កាលបរិច្ឆេទកំណត់រយៈពេល ៣០ ថ្ងៃសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍ គឺនៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩។

4. សហមេធាវីអន្តរជាតិទាំងពីរនាក់របស់ក្រុម រួមមាន កញ្ញា Diana Ellis, QC និងទីប្រឹក្សាផ្នែកច្បាប់ កញ្ញាKarlijin van der Voort មានធុរៈផ្ទាល់ខ្លួនដែលបានគ្រោងទុកពីមុន ដែលធ្វើឲ្យពួកគេជួបការលំបាកក្នុងការដោះស្រាយបញ្ហានៅខែសីហានេះ ខណៈដែលបញ្ហាដែលត្រូវលើកនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ គឺជាបញ្ហាស្មុគស្មាញដែលត្រូវការជំនួយពីសមាជិកទាំងអស់របស់ក្រុម។ មេធាវីការពារសូមស្នើថា នេះគឺជាមូលហេតុសាកសម្បំផុតសម្រាប់ការអនុញ្ញាតនូវការពន្យាពេលវេលាកំណត់ អនុលោមទៅតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង។

5. មេធាវីការពារក្តីស្នើសុំពន្យាពេល ១៤ ថ្ងៃ។ ប្រសិនបើអនុញ្ញាត មេធាវីការពារក្តីនឹងមិនជំទាស់ទៅលើសំណើស្រដៀងគ្នានេះ ដោយសហព្រះរាជអាជ្ញា ឬភាគីដទៃទៀត ដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នេះ។

6. មេធាវីការពារស្នើថា អង្គបុរេជំនុំជម្រះចេញសេចក្តីបង្គាប់ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើបានទៅភាគីទាំងអស់ ឲ្យដាក់ការឆ្លើយតបចំពោះសំណើនេះហើយ

[1] មិនទាន់បានជូនដំណឹងទេនៅថ្ងៃដាក់សំណើនេះ។

00357076

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អបជ)

ប្រសិនបើពួកគេពុំចង់ដាក់ការចម្លើយតបបែបនេះទេ ពួកគេត្រូវជូនដំណឹងអង្គបុរេជំនុំជម្រះអំពីការសម្រេចចិត្តបែបនេះ។

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកការជូនដំណឹពីបណ្ដឹងឧទ្ធរណ៍នេះដោយក្ដីគោរព។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់លោក អៀង ធីរិទ្ធ | ៣១ កក្កដា ២០០៩ | លោក ផាត់ ពៅស៊ាង<br>កញ្ញា Diana ELLIS QC | ភ្នំពេញ | |